ធ៧-០២-២២០ ប្រ.ក

# ប្រកាស
# ស្តីពី
# ប្រតិបត្តិការលើមូលប័ត្ររបស់ធនាគារ
# ដែលមានអាជ្ញាប័ណ្ណ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

**ប្រការ ១**.-

ធនាគារជាតិនៃកម្ពុជាគាំទ្រ និងបង្កលក្ខណៈអំណោយផលដល់ការរីកលូតលាស់ និងកិច្ចអភិវឌ្ឍន៍នៃទីផ្សារមូលប័ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលការណ៍សុវត្ថិភាព ភាពរឹងមាំ និងប្រសិទ្ធភាពនៃប្រព័ន្ធហិរញ្ញវត្ថុ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជានឹងសំរបសំរួលនីតិវិធីគណនេយ្យ និងប្រតិបត្តិការរបស់ខ្លួនក្នុងគោលបំណងសំរួលការផ្តល់ឥណទាន និងការជួញដូរមូលប័ត្រជាអន្តរធនាគារ។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជា នឹងអនុវត្តនូវស្តង់ដារ ពិសេសសម្រាប់ធ្វើការត្រួតពិនិត្យធនាគារទាំងឡាយដែលដើរតួជាជើងសារការី ឬជាប្រតិបត្តិករមូលប័ត្រ។

**ប្រការ ២**.-

ធនាគារត្រូវបានចាត់ទុកថាជាប្រតិបត្តិករជើងសារការី ឬជាប្រតិបត្តិករមូលប័ត្របើធនាគារនោះផ្តល់ការធានា ឬជួញដូរ ឬធ្វើប្រព្រឹត្តកម្មមូលប័ត្រ។ ប្រសិនបើការទិញនិងលក់មូលប័ត្ររយៈពេលខ្លីតាមរូបភាពដដែលៗបង្ហាញឱ្យប្រតិបត្តិករមូលប័ត្រ ឬវិនិយោគិនដទៃទៀតយល់ឃើញថា ធនាគារធ្វើប្រតិបត្តិការលើមូលប័ត្រ ធនាគារនោះត្រូវបានចាត់ទុកថាធ្វើសកម្មភាពជួញដូរមូលប័ត្រ ដោយពុំគិតដល់ផ្នែកណាមួយនៃធនាគារជាអ្នកចាត់ចែងដំណើរប្រតិបត្តិការទាំងនោះឡើយ។

**ប្រការ ៣**.-

ការសំរបសំរួលនីតិវិធីប្រតិបត្តិការនិងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា រួមមានការអនុញ្ញាតឱ្យធនាគារផ្ទេរមូលនិធិពីគណនីចរន្តរបស់ខ្លួនទៅកាន់គណនីចរន្តរបស់ធនាគារដទៃនៅធនាគារជាតិនៃកម្ពុជាតាមវិធីប្រើបញ្ជាទូទាត់តាមទូរស័ព្ទជាលើកដំបូងទៅធនាគារជាតិនៃកម្ពុជា ដោយមានការសួរបញ្ជាក់តបវិញ។ ដើម្បីអនុវត្តវិធីនេះ ធនាគារបញ្ជាផ្ទេរប្រាក់និងធនាគារទទួលប្រាក់ចាំបាច់ត្រូវធ្វើកិច្ចព្រមព្រៀងគោលដែលត្រូវផ្ញើជូនមកធនាគារជាតិនៃកម្ពុជាជាមុន។ កិច្ចព្រមព្រៀងនេះត្រូវចែងអំពីប្រការទាំងឡាយ បង្ហាញពីការស្រុះស្រួលគ្នាធ្វើប្រតិបត្តិការបែបនេះ និងមានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាលរបស់សាម៉ីធនាគាររៀងៗខ្លួនផងដែរ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជានឹងបង្កើតប្រព័ន្ធចុះបញ្ជីសម្រាប់មូលប័ត្ររបស់រដ្ឋាភិបាល នៅពេលណាដែលមូលប័ត្រនេះត្រូវបានចេញផ្សាយ។ កិច្ចព្រមព្រៀងផ្ទេរតាមទូរស័ព្ទដូចគ្នាខាងលើសម្រាប់ការជួញដូរមូលប័ត្ររបស់រដ្ឋាភិបាលក្នុងចំណោមធនាគារនឹងត្រូវបង្កើតឡើងនៅពេលនោះ។

**ប្រការ ៤**.-

ធនាគារជាតិនៃកម្ពុជានឹងធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់ធនាគារដែលធ្វើសកម្មភាពជួញដូរមូលប័ត្រ។ នីតិវិធីនៃការត្រួតពិនិត្យរួមមានការត្រួតពិនិត្យមើលក្រុមប្រឹក្សាភិបាល និងការគ្រប់គ្រងការត្រួតពិនិត្យលើគោលនយោបាយនិងកំរិតហានិភ័យ ការថែរក្សាឯកសារកត់ត្រានិងភាពត្រឹមត្រូវនៃប្រតិបត្តិការ ការអនុវត្តការ

ជួញដូរ និងការបែងចែកភារកិច្ចការងារបណ្តុះបណ្តាល និងកម្មវិធីផ្តល់កំរៃដល់ប្រតិបត្តិករ និងបុគ្គលិក ការកាន់កាប់មូលប័ត្រនិងការកត់ត្រាការជួញដូរ និងទិដ្ឋភាពដទៃទៀតនៃប្រតិបត្តិការទាំងឡាយដែលពាក់ព័ន្ធ។ ការត្រួតពិនិត្យបែបនេះអាចជាផ្នែកមួយនៃការត្រួតពិនិត្យជារួមទៅលើធនាគារ ឬអាចមានលក្ខណៈដោយឡែកពីការត្រួតពិនិត្យដទៃទៀត។

**ប្រការ ៥**.-

រាល់របាយការណ៍ត្រួតពិនិត្យទាំងអស់ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា គឺជាកម្មសិទ្ធិផ្តាច់មុខរបស់ធនាគារជាតិនៃកម្ពុជា ហើយមិនអាចថតចម្លង ឬបញ្ជូនដោយគ្មានការឯកភាពពីធនាគារជាតិនៃកម្ពុជាឡើយ លើកលែងតែក្នុងករណីដែលច្បាប់អនុញ្ញាត។

**ប្រការ ៦**.-

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលនៃធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឹងម៉ាត់ នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៨**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០២

**ទេសាភិបាល**

ហត្ថលេខា និងត្រា: **ជា ចាន់តូ**